ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខ : 3 ៤ ៤ • ប្រក.សក.ពក

ភ្នំពេញ .ថ្ងៃទី 31 ខែ 8 ឆ្នាំ ២០០១

ទីស្ដីការគណៈរដ្ឋមន្ត្រី
មកដល់ថ្ងៃទី 7 ខែ 9 ឆ្នាំ 2001
ម៉ោង 15 លេខ 281

# ប្រកាស

## ស្ដីអំពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់មន្ទីរ សាធារណការនិងដឹកជញ្ជូន ខេត្ត- ក្រុង

## រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ .ចុះថ្ងៃទី ៣០.១១.១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤.០១.១៩៩៦ ស្ដីពីការបង្កើតក្រសួង សាធារណការ និង ដឹកជញ្ជូន ។

-បានឃើញ អនុក្រឹត្យលេខ ១៤ / អនក្រ .បក ចុះថ្ងៃទី ០៣.០៣.១៩៩៨ ស្ដីពីរៀបចំនិងការប្រព្រឹត្តិទៅរបស់ ក្រសួងសាធារណការ និង ដឹកជញ្ជូន ។

-យោងតាមការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់អំពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អង្គភាពមូលដ្ឋាន ចំណុះក្រសួងសាធារណការនិងដឹកជញ្ជូន ហៅថា " មន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្ត-ក្រុង " ដែលមានភារកិច្ច ជាអាទិ៍ :

-តំណាងអោយស្ថាប័នក្រសួង លើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល អំពីវិស័យសាធារណការ និង ដឹកជញ្ជូន នៅមូលដ្ឋានខេត្ត-ក្រុង ។

-គ្រប់គ្រងលើផ្នែករដ្ឋបាល និង រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស មន្ត្រី-រាជការក្រោមឱវាទ ។

-គ្រប់គ្រងត្រួតពិនិត្យការដឹកជញ្ជូន គ្រប់ប្រភេទ រាប់ទាំងមធ្យោបាយដឹកជញ្ជូន ទីចំណត និងការដ្ឋានជួសជុល កែច្នៃ តម្លើងមធ្យោបាយដឹកជញ្ជូនទាំងនោះ តាមការកំណត់របស់ក្រសួង ។

-គ្រប់គ្រងថែរក្សារាល់សមិទ្ធិ ហេដ្ឋារចនាសម្ពន្ធ័ដឹកជញ្ជូនជាអាទិ៍ ផ្លូវថ្នល់ ស្ពាន កំពង់ផែ ( លើកលែងតែកំពង់ផែស្វយ័តក្រុងភ្នំពេញ និង កំពង់ផែស្វយ័តក្រុងព្រះសីហនុ ) ព្រលានយន្តហោះ ប្រពន្ធ័លូ ... ស្ថានីយបម្រោះទឹកកខ្វក់ កំពង់ដរ អាគារ ដីធ្លី ស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ។

-គ្រប់គ្រង ថែរក្សា អនាម័យសាធារណៈ ក្នុងខេត្ត-ក្រុង តាមដងផ្លូវជាតិ និង ផ្លូវខេត្តនានា ។

-ស្រាវជ្រាវលើកគំរោងផែនការអភិវឌ្ឍន៍ លើវិស័យសាធារណការនិងដឹកជញ្ជូន នៅមូលដ្ឋានខេត្ត-ក្រុង

**ប្រការ ២ :** មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្ត-ក្រុង ដឹកនាំដោយ នាយក មន្ទីរម្នាក់ ឬ អមដោយ នាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**ប្រការ ៣ :** រចនាសម្ព័ន្ធដឹកនាំ និង គ្រប់គ្រង មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង រួមមាន :

ក/ **ការិយាល័យកណ្តាលរបស់មន្ទីរ :**

- ការិយាល័យ រដ្ឋបាល បុគ្គលិក
- ការិយាល័យ ផែនការ គណនេយ្យ
- ការិយាល័យ សាធារណការ
- ការិយាល័យ ដឹកជញ្ជូន

ខ/ **អង្គភាពក្រោមឱវាទមន្ទីរ :**

- អង្គភាពគ្រឿងចក្រ
- អង្គភាពស្ពានថ្នល់
- អង្គភាពរបើសក្រុង
- អង្គភាព ជលមាគ៌ា និង កំពង់ផែ
- អង្គភាព អគ្គីសនីបំភ្លឺសាធារណៈ
- អង្គភាពសួនច្បារ រុក្ខជាតិ
- អង្គភាពសំអាតទីក្រុង
- អង្គភាពគ្រប់គ្រង លូទឹក និង ស្ថានីយ៍ចម្រោះទឹកស្អុយ

គ/ **ការិយាល័យសាធារណការ និងដឹកជញ្ជូន ខ័ណ្ឌ - ស្រុក :**

**ប្រការ ៤ :** ការកំណត់ចំនួនអង្គភាពក្រោមឱវាទមន្ទីរ ដែលចែងក្នុងប្រការ ៣ ចំណុច " ខ " ខាងលើ អាស្រ័យដោយ មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង ពិនិត្យ សុំយោបល់ពីក្រសួង តាមភូមិសាស្ត្រ និងតម្រូវការអភិវឌ្ឍន៍របស់មូលដ្ឋានជាក់ស្តែង ។

**ប្រការ ៥ :** ការិយាល័យនីមួយៗដឹកនាំដោយ នាយការិយាល័យមួយរូប និង អមដោយនាយរងការិយាល័យមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

អង្គភាពនិមួយៗ ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អង្គភាពចំណុះមន្ទីរ សមមូលថ្នាក់ការិយាល័យកណ្តាល នៃ មន្ទីរនានាជុំវិញខេត្ត-ក្រុង ។

**ប្រការ ៦ :** មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត-ក្រុង និមួយ ៗ មានភារកិច្ចរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់មន្ទីរ ដោយលំអិតនូវតួនាទីភារកិច្ច របស់ថ្នាក់ការិយាល័យ អង្គភាព ជូនក្រសួងពិនិត្យសំរេច ។

**ប្រការ ៧ :** ប្រកាសនេះ នឹង ត្រូវធ្វើនិយ័តកម្ម តាមអនុក្រឹត្យនៅពេលខាងក្រោយ ។

**ប្រការ ៨ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩:** នាយកខុទ្ទកាល័យ , អគ្គនាយក នៃ អគ្គនាយកដ្ឋានរដ្ឋបាល , អគ្គនាយក នៃ អគ្គនាយកដ្ឋានសាធារណការ អគ្គនាយក នៃ អគ្គនាយកដ្ឋានដឹកជញ្ជូន , អគ្គាធិការ នៃ អគ្គាធិការដ្ឋាន និង នាយកមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តរៀងៗខ្លួនតាម ខ្លឹមសារនៃប្រកាសនេះ ដែលមានអានុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

ឃី តាំងលឹម

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការមុខងារសាធារណៈ
- សាលា ខេត្ត-ក្រុង

**ដើម្បីជូនជ្រាបជាព័ត៌មាន**

- ដូចប្រការ ៩
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- គ្រប់មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង

**ដើម្បីអនុវត្ត**